**ភស្តុតាងស្តីពីទង្វើមិនល្អរបស់ជនជាប់ចោទ (evidence of bad character) (J R Spencer, Evidence of Bad Character, 3rd ed., 2016, pp. 35-48)**

**ពាក្យគន្លឹះ÷** ភស្តុតាងស្តីពីទង្វើមិនល្អរបស់ជនជាប់ចោទ (EBC)

១. ក្នុងដំណើរការក្តីរឿងព្រហ្មទណ្ឌ មានភស្តុតាងជាច្រើន មានលក្ខណៈវិទ្យាសាស្ត្រទូទៅ ឬទាក់ទងនឹងបុគ្គល ដែលអាចបង្ហាញពីការប្រព្រឹត្ត ឬសម្រាប់បន្ថែមនូវទោស (ស្ថានទម្ងន់)។ ក្នុងនោះ វាមានភស្តុតាងស្តីពីទង្វើមិនល្អរបស់ជនជាប់ចោទ។ តើវាមានវិសាលភាពយ៉ាងណា? តើគេទទួលយកបានតាមវិធីអ្វី?

២. EBC... *ជាភស្តុតាងឬការសម្តែងឆ្ពោះទៅរកការប្រព្រឹត្តទង្វើ ទង្វើមិនត្រឹមត្រូវ ដោយជនជាប់ចោទ ក្រៅពីភស្តុតាងដែល (ក) ជាអង្គហេតុនៃបទល្មើសដែលត្រូវបានចោទឬ (ខ) ភស្តុតាងនៃទង្វើខុសឆ្គងទាក់ទិននឹងការស៊ើបអង្កេត ឬចោទប្រកាន់នៃបទល្មើសនោះ។*[1]

៣. មានភស្តុតាងនៃបទល្មើសត្រូវបានចោទ។ ភស្តុតាងនេះ មិនដូចគ្នានឹងភស្តុតាងទាក់ទងនឹងបទល្មើស ឬភស្តុតាងដែលជាគន្លឹះសម្រាប់ការចោទប្រកាន់។ ជាក់ស្តែង ការក្លែងលិខិតឆ្លងដែន ជាភស្តុតាងពាក់ព័ន្ធនឹងបទចូលក្នុងប្រទេសខុសច្បាប់។ សម្រាប់ភស្តុតាង អំពីទង្វើមិនសមស្រប (misconduct) ក្នុងអំឡុងពេលស៊ើបសួរ មានដូចជា ការតវ៉ានឹងការឃាត់ខ្លួន។ ទាំងបីប្រភេទនេះ មិនមែនជា EBC ទេ។

៤. EBC មានដូចជា ទង្វើដែលចាត់ជាបទល្មើសកន្លងមក ទោះបីប្រភេទអ្វីក៏ដោយ។ ភស្តុតាងនោះដូចជា ការនិយាយកុហក ការផឹកជាតិអាល់កុលលើសកម្រិត ការខកខានមិនសងបំណុល ការមិនគោរពបញ្ញា អវត្តមាននិងទម្រង់នៃទង្វើឆ្គាំឆ្គងដទៃទៀតនៅកន្លែងការងារ។ បទល្មើសដែលត្រូវបានចោទ ត្រូវសម្រេចជាស្ថាពរថាមានទោស។ ជាការអនុវត្ត ចៅក្រមមិនទទួលជាភស្តុតាង EBC ទេ ការណ៍គ្រាន់តែមានការចោទថាបុគ្គលនោះ បានប្រព្រឹត្តអ្វីមួយ។

៥. អ្វីទៅជាការសម្តែងឆ្ពោះទៅការប្រព្រឹត្តបទល្មើស (disposition towards)? វាអាចជាភស្តុតាងស្តីពីការប្រមូលព័ត៌មានដើម្បីចូលទៅលួចប្លន់ ក្បួនប្រព្រឹត្តអំពើភេរវកម្ម ឬរូបភាពអាសអាភាសកុមារ។

[1] Section 98 of the Criminal Justice Act 2003 (the UK): Are evidence of, or of a disposition towards, misconduct on his part, other than evidence which (a) has to do with the alleged fact of the offense with which the defendant is charged, or (b) is evidence of misconduct in connection with the investigation or prosecution of that offence.

**៦.** ទម្លើប៉ុនប៉ងសម្លាប់ខ្លួន មិនស្ថិតចូលជា EBCទេ។ ពាក់ព័ន្ធនឹងបញ្ហានេះ សំណួរសួរជាចម្បងថាតើការបំពានផ្លូវភេទកន្លងមកជាEBC?។ វានៅមានភាពមិនច្បាស់លាស់ ដោយសារវាពាក់ព័ន្ធនឹងជីវិតឯកជន។ ពាក់ព័ន្ធនឹងចំណុចនេះ ការទទួលឬមិនទទួលEBC ត្រូវពិចារណាថាមានការប៉ះពាល់ដល់សិទ្ធិសេរីភាពបុគ្គល ដូចជាសិទ្ធិជីវិតឯកជន។ ជាមួយគ្នានេះ វាក៏អាចប៉ះនឹងគោលការណ៍សមភាពនៃភាគី (equality of arms) ក្នុងន័យថា ការទទួលយកEBC នឹងមិនចាំបាច់មានការអនុញ្ញាតពីតុលាការ (judicial leave)ទេ ក៏ប៉ុន្តែ ការទទួលយកEBC ពាក់ព័ន្ធសាក្សីនៃរដ្ឋអាជ្ញា ត្រូវសុំការអនុញ្ញាតពីចៅក្រម។ វាអាចប៉ះនឹង គោលការណ៍សន្មតជាមុនថាគ្មានទោស ដោយសារ មានដាក់បន្ទុកភស្តុតាងដល់ជនជាប់ចោទជាអ្នកបង្ហាញភស្តុតាង។ ជាចុងក្រោយ វាអាចប៉ះដល់គោលការណ៍ហាមកាត់សេចក្តីពីរដងក្នុងរឿងហេតុតែមួយផងដែរ ដោយសារ ការលើកយកមកនូវអង្គហេតុល្មើសពីអតីតកាលរបស់ជនជាប់ចោទ ចង់មិនចង់ ចៅក្រមនឹងសម្រេចថា តើជនជាប់ចោទបានប្រព្រឹត្តមែនឬទេ? គោលការណ៍ទាំងនេះជាធាតុផ្សំនៃសិទ្ធិទទួលបានការកាត់សេចក្តីដោយយុត្តិធម៌។